# របាយការណ៍ស្តីពី ការប្រើប្រាស់ធនធានរដ្ឋ សម្រាប់បម្រើឲ្យគណបក្សនយោបាយ

ខុមហ្វ្រែល COMFREL

ខែឧសភា ឆ្នាំ២០១២

# ឧបត្ថម្ភដោយ

សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការខុមហ្វ្រែល ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយ ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ ។


ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៤ ៧៤៥

អ៊ីម៉េល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. បទបញ្ញត្តក្នុងការប្រើប្រាស់ធនធានរដ្ឋ ........ 2

៣. វធីសាស្ត្រសង្កេត ........ 4

៤. ការរកឃើញ ........ 5

៤.១. ការវិភាគប្រព័ន្ធផ្សព្វផ្សាយ និងការសង្កេតដោយផ្ទាល់របស់ខុមហ្វ្រែល ........ 5

៤.១.១ ការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្សរបស់រដ្ឋ ........ 5

៤.១.២ ការប្រើប្រាស់មិនត្រឹមត្រូវកន្លែងសាធារណៈ ........ 7

៤.១.៣ ភាពមិនត្រឹមត្រូវនៃប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ........ 7

៤.២. ការស្ទាបស្ទង់ទស្សនៈម្ចាស់ឆ្នោតរបស់អង្គការខុមហ្វ្រែល ........ 8

៥. សន្និដ្ឋាន ........ 14

ឧបសម្ព័ន្ធ ១៖ វិធីសាស្ត្រនៃការសង្កេត ........ 17

ឧបសម្ព័ន្ធទី ២៖ ឯកសារផ្សេងៗ និង តារាងសកម្មភាពរបស់មន្ត្រីរដ្ឋចូលរួមសកម្មភាពគណបក្សនយោបាយ ........ 28

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋក្នុងគោលបំណងបំរើឲ្យគណបក្សនយោបាយ។ តាមរយៈការសង្កេតរបស់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិកន្លងមកបានបង្ហាញថា ការប្រើប្រាស់ធនធានរដ្ឋដោយគណបក្សនយោបាយ នៅតែជាគំរូដ៏ធម្មតាមួយក្នុងដំណើរការនយោបាយរបស់ប្រទេសកម្ពុជា ដែលកើតឡើងមិនត្រឹមតែក្នុងពេលការឃោសនាបោះឆ្នោតតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកើតឡើងនៅក្នុងរយៈពេលមិនមែនកំឡុងពេលនៃការបោះឆ្នោត។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានរកឃើញនូវភាពមិនប្រក្រតីយ៉ាងច្រើនដែលក្នុងនោះរួមបញ្ចូលទាំងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដូចជា អាគារ យានជំនិះរបស់រដ្ឋ ព្រមទាំងបុគ្គលិករដ្ឋ ដែលរួមបញ្ចូលទាំងទាហាន ប៉ូលីសធ្វើការគាំទ្រការឃោសនាបោះឆ្នោត ក៏ដូចជាការឃោសនារបស់គណបក្សនយោបាយដែលមិនមែនជាកំឡុងពេលនៃការបោះ ឆ្នោត។ ការសង្កេតជាក់ស្តែងចំពោះការប្រើប្រាស់ធនធានរដ្ឋត្រូវបានឲ្យផលប្រយោជន៍យ៉ាងច្រើន និងលើសលុបចំពោះគណបក្សប្រជាជនកម្ពុជា និងបានធ្វើឲ្យមានការប្រកួតប្រជែងក្នុងសៃវៀននយោបាយដែលមិនស្មើភាពគ្នា។ ការលើកឡើងនូវសំនួរទាំងនេះ ថាតើប្រសិនបើការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌អាចនៅក្រោមលក្ខខណ្ឌនេះដែរឬទេ ។

ហេតុដូច្នេះ ខុមហ្វ្រែលបានចាប់ផ្តើមផ្តោតយកចិត្តទុកដាក់ទៅលើករណីដែលគួរឲ្យព្រួយបារម្ភនេះ និងបានសំរេចចិត្តនៅឆ្នាំ២០១១ ធ្វើការត្រួតពិនិត្យទៅលើសក្តានុពលការប្រើប្រាស់ធនធានរបស់រដ្ឋដែលកើតឡើងរហូតមក។ តាមរយៈរបាយការណ៍ ការកែទំរង់ប្រជាធិបតេយ្យ និងការបោះឆ្នោតឆ្នាំ២០១១[1] ក៏បានលើកឡើងពីការប្រើប្រាស់ធនធានរបស់រដ្ឋ គឺធ្វើឲ្យមានភាពមិនស្មើគ្នាក្នុងការប្រកួតប្រជែងផ្នែកនយោបាយ និងធ្វើឲ្យប៉ះពាល់ដល់ការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌។ របាយការណ៍បានឆ្លុះបញ្ចាំងនូវការប្រើប្រាស់ធនធានរដ្ឋយ៉ាងលំអិត និងល្អិតល្អន់ទៅលើអ្វីដែលច្បាប់បញ្ញត្តិ និងដែលធ្វើឲ្យជះឥទ្ធិពលដល់ការប្រកួតប្រជែងរបស់គណបក្សនយោបាយ ព្រមទាំងដំណើរការប្រជាធិបតេយ្យ។ នេះជារបាយការណ៍សង្កេតលើកដំបូងរបស់ខុមហ្វ្រែល ដែលក្នុងគោលបំណងឲ្យសាធារណជនបានយល់ដឹង និងជ្រាបទៅលើបញ្ហា ព្រមទាំងពង្រឹងការគោរពច្បាប់ដែលបានបញ្ញត្តិក្នុងការហាមការប្រើប្រាស់ធនធានរដ្ឋដែលបំរើឲ្យគណបក្សនយោបាយណាមួយ។ វិធីសាស្ត្រនៃការសិក្សាសំរាប់ការសង្កេតតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (សង្កេតមិនផ្ទាល់) ត្រូវបានរៀបចំឡើង និងពឹងផ្អែកទៅលើការវិភាគប្រព័ន្ធផ្សព្វផ្សាយ និងការស្ទាបស្ទង់ទៅលើម្ចាស់ឆ្នោតដើម្បីធ្វើការសិក្សាបញ្ជាក់ពីករណីប្រើប្រាស់ធនធានរដ្ឋ។ ទោះបីជារបាយការណ៍នេះ នឹងត្រូវបញ្ចូលការសង្កេតដោយផ្ទាល់នៃការសង្កេតរបស់បណ្តាញខុមហ្វ្រែលនៅទូទាំងប្រទេស ប៉ុន្តែនៅពេលនេះមិនទាន់មានរបាយការណ៍សង្កេតដោយផ្ទាល់ទេ ដោយសារតែបញ្ហាធនធាន។ ការសង្កេតតាំងពីខែកញ្ញា ឆ្នាំ២០១១ ដល់ខែមករា ឆ្នាំ២០១២ និងក្រុមការងារនៃការសិក្សាសង្កេតនេះ ត្រូវបានធ្វើឡើងដោយកញ្ញា គង់ រ៉ាវីន លោក សុខ ពិទូរ្យ លោក កន សាវាង្ស លោកតាំង សុខា លោក អ៊ូ រិទ្ធី កញ្ញា លី ម៉ាលីនដែលរួមមាន អ្នកសង្កេតស្ម័គ្រចិត្តរួមមានកញ្ញា គិន រីដារស្មី កញ្ញា ង៉ុយ សុខវ័ន្ត កញ្ញា ស៊ូ ផារិន លោក លី ប៊ុនប៉េង លោក ហ៊ាង ធីរិទ្ធ លោក សុខ ឧត្តម លោក ហេង សុធា លោក ឌីម រដ្ឋា និងលោក ហេង សុខហ៊ុល

[1] ខុមហ្វ្រែលៈ របាយការណ៍ប្រចាំឆ្នាំស្តីពីប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់ ២០១១ ទំព័រ ២០-២១ (www.comfrel.org)

ក្រោមការដឹកនាំដោយលោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល។

## ២. បទបញ្ញត្តក្នុងការប្រើប្រាស់ធនធានរដ្ឋ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិ និងសេរីភាពនយោបាយដើម្បីចូលរួមនៅក្នុងសង្គម និងកិច្ចការនយោបាយដោយគ្មានការរើសអើង។ ទោះបីយ៉ាងណា ច្បាប់បានកំនត់សិទ្ធិនយោបាយចំពោះក្រុមមួយចំនួន ដែលបានផ្តោតយ៉ាងច្បាស់ទៅលើមន្ត្រីរបស់រដ្ឋ ដែលមិនរាប់បញ្ចូលមន្ត្រីជាប់ឆ្នោត ឬមន្ត្រីនយោបាយរបស់រដ្ឋាភិបាល។ ក្នុងរបាយការណ៍មន្ត្រីរបស់រដ្ឋនិយាយទៅដល់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលជាដើម។ ក្រុមទាំងនេះរួមជាមួយបុព្វជិត(ព្រះសង្ឃ) មិនត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសកម្មភាពគាំទ្រ ឬប្រឆាំងទៅលើគណបក្សនយោបាយណាមួយ បើទោះបីជាក្រុមនេះមានសិទ្ធិក្នុងការបោះឆ្នោត និងជាសមាជិកនៃគណបក្សនយោបាយណាមួយ ឬអាចចូលរួមជាបេក្ខជនក្នុងការបោះឆ្នោត។ ប៉ុន្តែលុះត្រាតែមានលក្ខខណ្ឌដែលពួកគេត្រូវតែលាលែងពីតំណែងមុន ដូចជាមន្ត្រីរបស់រដ្ឋដែលបានកំណត់នៅខាងលើ និងករណីព្រះសង្ឃដែលត្រូវបោះបង់ជាបុព្វជិត ឬព្រះសង្ឃ៧ថ្ងៃមុន ថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោតផ្លូវការ។ ច្បាប់កម្ពុជាក៏បានហាមឃាត់គណបក្សនយោបាយក្នុងការរៀបចំរចនាសម្ព័ន្ធចាត់តាំងនៅក្នុងស្ថាប័នសាសនា តុលាការ កងកម្លាំងប្រដាប់អាវុធ និងនគរបាលជាតិ ។ បើតាមបញ្ញត្តិហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋ ជាពិសេសទៅលើការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋក្នុងគោលបំណងបំរើឲ្យគណបក្សនយោបាយ។

***មាត្រា១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ (១៩៩៧)*** *បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកលាំងនគរបាលជាតិទេ។ ជនណាដែលបានប្រព្រឹត្តល្មើស និងវាក្យខ័ណ្ឌទី ២ នៃមាត្រា១៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនមួយលានរៀល* (មាត្រា ៤០ នៃច្បាប់ស្តីពីគណបក្សនយោបាយ ១៩៩៧)

***មាត្រា ៣៧នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា*** *មន្ត្រីរាជការស៊ីវិលត្រូវមានអព្យាក្រិតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយដូចខាងក្រោម៖*

- *ធ្វើការដើម្បីផលប្រយោជន៍បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ។*
- *ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។*

*ការប្រព្រឹត្តិផ្ទុយនឹងមាត្រានេះចាត់ទុកជាកំហុស និងការវត្តាំផ្តងក្នុងវិជ្ជាជីវៈ។*

***មាត្រាទី ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ*** *យោធិនមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត។ ក៏ប៉ុន្តែការប្រើសិទ្ធិ និងសេរីភាពខ្លះត្រូវមានការកម្រិតស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ។ យោធិនត្រូវមានអព្យាក្រិតភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ និងប្រើប្រាស់សម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយណាមួយ។*

***ក្រមសីលធ៌មសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ***

*យោធិននៃកងយោធពលខេមរភូមិន្ទគ្រប់រូបត្រូវ៖*

– *ប្រកាន់ខ្ជាប់នូវជំហរអព្យាក្រិតអត់លំអៀងក្នុងមុខនាទី និងក្នុងគ្រប់សកម្មភាពការងារ*

*យោធិននៃកងយោធពលខេមរភូមិន្ទមិនត្រូវ៖*

– *យកមុខងារ និងសម្ភារៈរបស់រដ្ឋទៅប្រើប្រាស់ដើម្បីបំរើសកម្មភាពនយោបាយគណបក្សណាមួយឡើយ*

*ការស្លៀកពាក់ឯកសណ្ឋាន៖*

*ការស្លៀកពាក់ឯកសណ្ឋានយោធាទៅចូលរួមក្នុងសកម្មភាពឯកជន និងជាសាធារណៈក្នុងការប្រជុំគណបក្សនយោបាយ និងការឃោសនានយោបាយ ត្រូវហាមឃាត់ដាច់ខាត។*

មិនតែប៉ុណ្ណោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) បានអនុម័ត ឬរៀបចំបទបញ្ជា និងនីតិវិធី ដែលបានហាមឃាត់មន្ត្រីរដ្ឋដែលបានកំណត់ខាងលើ ចូលរួមនៅក្នុងសកម្មភាពគណបក្សនយោបាយ បើទោះបីជាបទបញ្ជា និងនីតិវិធីទាំងនេះមានភាពមិនច្បាស់ដែលគួរតែធ្វើការកែប្រែ។ ដោយផ្អែកលើមាត្រា៣៥នៃច្បាប់ស្តីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(LEMNA) និងមាត្រា៤៧ថ្មីនៃច្បាប់ស្តីពី ការជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់បានចែងថា មន្ត្រីរដ្ឋដែលបានកំនត់ខាងលើត្រូវតែលាលែងពីតំណែងមុនការ ថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត និងមុនឈរជាបេក្ខជន ។

ប្រការ៧.៦ នៃបញ្ជា និងនីតិវិធីរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) សំរាប់ការឃោសនាបោះឆ្នោត(សំរាប់ការជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២) ក៏បានចែងថា *មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ៖*

- *ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោតដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។*
- *ប្រើប្រាស់អាគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសម្លេងឆ្នោត។*
- *ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ។*

យ៉ាងណាមិញ ប្រការនេះបានចែងផ្ទុយទៅនឹងប្រការផ្សេងទៀតនៅក្នុងបទបញ្ជា និងនីតិវិធីរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) (ប្រការ ៨.៧ នៃបទបញ្ជា និងនិតិវិធីសម្រាប់ការជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២) ដែលបានអនុញ្ញាតសកម្មភាពគណបក្សនយោបាយរបស់មន្ត្រីរដ្ឋដែលបានកំណត់ខាងលើ *បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន ឬ/និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិនិងមន្ត្រីតុលាការដែលប្រព្រឹត្តល្មើសនឹងប្រការនេះ និងប្រការ៧.៦ខាងលើ ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា១៣១នៃច.ប.ត.រ។* ប្រការនេះមិនត្រូវចែងដូចគ្នាជាមួយនឹងច្បាប់ស្តីពីគណបក្សនយោបាយ(១៩៩៧) និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិល និងច្បាប់ស្តីពីលក្ខន្តិកៈកងយោធពលខេមរភូមិន្ទ ដែលបានហាមឃាត់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ នគរបាលជាតិ និង

មន្ត្រីតុលាការអនុវត្តនូវសកម្មភាពគាំទ្រគណបក្សនយោបាយណាមួយ។

មិនតែប៉ុណ្ណោះបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) បានបកប្រែ អព្យាក្រឹត្យភាពជាពីរនិយាម(ឬស្តង់ដាពីរ) ដែលមានការខុសរវាងមន្ត្រីរបស់រដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល សមាគមក្នុងស្រុកធ្វើសកម្មភាពទាក់ទងទៅនឹងការឃោសនាបោះឆ្នោត និងសកម្មភាពនយោបាយ។ ប្រការ ៨.១០នៃបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២បានចែងថា *អង្គការក្រៅរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ជំហរអព្យាក្រឹត្យមិនលំអៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ (...) មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម៖*

- *ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយ បេក្ខជនឬអ្នកគាំទ្រណាមួយ (...)*
- *ចេញសេចក្តីថ្លែងការណ៍ ឬសកម្មភាពណាមួយគាំទ្រ ឬបង្ហាញភាពលម្អៀង ឬប្រឆាំងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។ (...) ផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ជាធនធានមនុស្ស ឬមធ្យោបាយ ផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។*

មិនដូចពីមន្ត្រីរបស់រដ្ឋដូចបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) មិនបានលើកពេលវេលាឲ្យអង្គការក្រៅរដ្ឋាភិបាល អាចធ្វើសកម្មភាពនយោបាយបន្ទាប់បីបំពេញម៉ោងការងារ ឬក្រៅភារកិច្ច។

## ៣. វិធីសាស្ត្រសង្កេត

ផ្អែកលើការពិព៌ណនាបទបញ្ញត្តិច្បាប់ខាងលើ ប្រការដែលចែងមិនច្បាស់ខ្លះ និងខុមហ្វ្រែលបានធ្វើការសង្កេតលក្ខណៈជាប្រព័ន្ធ ប្រសិនបើមន្ត្រីរដ្ឋដែលកំណត់ខាងលើ និងគណបក្សនយោបាយធ្វើការអនុវត្តនូវច្បាប់ដែលមាន។ ការសង្កេតបានធ្វើឡើងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២។ សំរាប់ការសង្កេតនេះដែរ ខុមហ្វ្រែលអនុវត្តនូវវិធីសាស្ត្រ៣យ៉ាង។ វិធីសាស្ត្រទី១ គឺប្រើវិធីសាស្ត្រសង្កេតដោយផ្ទាល់តាមរយៈអ្នកសង្កេតការណ៍របស់ ខុមហ្វ្រែលនៅក្នុងប្រទេសកម្ពុជា ដែលនេះគឺជាមធ្យោបាយឲ្យអ្នកសង្កេតការណ៍ទាំងអស់មានវត្តមាននៅទីកន្លែង និងបានឃើញដោយផ្ទាល់ពីភាពមិនប្រក្រតី។ ទោះបីជាយ៉ាងណា ដោយសារតែធនធាននៅមានកំរិត ការសង្កេតដោយផ្ទាល់មិនត្រូវបានធ្វើឡើងនោះទេ។

ការសិក្សាដែលមានសារៈសំខាន់នេះក្លាយជាការរកឃើញ ដោយផ្អែកលើការសង្កេតតាមវិធីសាស្ត្រទី២ ដែលជាវិធីសាស្ត្រសង្កេតតាមប្រព័ន្ធផ្សព្វផ្សាយ។ ជាញឹកញាប់ ការប្រជុំគណបក្សនយោបាយ ការចែកអំណោយរបស់គណបក្សនយោបាយ គឺត្រូវបានផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុ ឬបានលេចឡើងនៅតាមសារព័ត៌មានមួយចំនួន ដែលជាមធ្យោបាយក្នុងការឃោសនបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយដូចជា ទូរទស្សន៍ និងវិទ្យុ ត្រូវបានថតទុកដោយខុមហ្វ្រែល និងបន្ទាប់មកធ្វើការវិភាគទៅលើការប្រើប្រាស់ធនធានរដ្ឋ។ ដូចគ្នាដែរ សារព័ត៌មានក៏ត្រូវបានធ្វើការសង្កេត។ ការប្រៀបធៀបដែលមានសារៈសំខាន់សំរាប់ការសិក្សានេះ ត្រូវបានរកឃើញផ្អែកលើវិធីសាស្ត្រទី៣ ដែលបានធ្វើតាមរយៈការសង្កេតស្រាវជ្រាវ ដោយធ្វើការសម្ភាសន៍ម្ចាស់ឆ្នោត ប្រសិនបើពួកគេបានសង្កេតឃើញមានការប្រើប្រាស់ធនធានរដ្ឋរបស់គណបក្សនយោបាយ។ ការសង្កេតស្រាវជ្រាវនេះដែរ ត្រូវបានអនុវត្តនៅកំរិតមូលដ្ឋានដូចជា កំរិតភូមិនៅគ្រប់២៤ខេត្ត/រាជធានី។ សំណាកនៃអ្នកសម្ភាសន៍ត្រូវបានប្រើដើម្បីកំណត់ពីការិយាល័យបោះឆ្នោតនៅទូទាំងថ្នាក់ឃុំ និងស្រុក ពីកន្លែងដែលម្ចាស់ឆ្នោតត្រូវបានជ្រើសរើសដោយចៃដន្យ។ សំរាប់ភាពលំអិតនៃវិធីសាស្ត្រសង្កេតស្រាវជ្រាវនេះអាចរកបាន

នៅខុមហ្វ្រែលភ្នំពេញ។

# ៤. ការរកឃើញ

## ៤.១. ការវិភាគប្រព័ន្ធផ្សព្វផ្សាយ និងការសង្កេតដោយផ្ទាល់របស់ខុមហ្វ្រែល

### ៤.១.១ ការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្សរបស់រដ្ឋ

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២ ខុមហ្វ្រែលបានសង្កេតឃើញមានការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្សរបស់រដ្ឋចំនួន២០០ករណី ដែលក្នុងនោះពុំមានលក្ខណៈជាប្រព័ន្ធក្នុងកាប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ជាក់ច្បាស់នៅក្នុងកំឡុងពេលនៃការសង្កេតនេះទេ ។ ក៏ប៉ុន្តែការសង្កេតឃើញមាន១៣ករណី ដែលរួមបញ្ចូលទាំងការប្រើប្រាស់អាគាររបស់រដ្ឋ និងទីធ្លា/បរិវេណរបស់រដ្ឋត្រូវបានប្រើប្រាស់សំរាប់ជាប្រយោជន៍គណបក្សនយោបាយ។ ករណីទាំងនេះ រួមបញ្ចូលគណបក្សប្រជាជនកម្ពុជាក៏បានដាក់តាំងនូវផ្លាកសញ្ញាគណបក្សនៅតាមទីសាធារណៈ អគាររដ្ឋាភិបាល សាលារៀន និងទីសាធារណៈផ្សេងទៀតសំរាប់កិច្ចប្រជុំគណបក្ស។ ជាមួយគ្នានេះដែរ ខុមហ្វ្រែលក៏បានរកឃើញនូវសញ្ញាអវិជ្ជមានជាច្រើនលើការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្សរបស់រដ្ឋ។ ករណីនេះគឺខុសពី «វិជ្ជាជីវៈមន្ត្រីរាជការ» ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីសហលក្ខណន្តិកៈមន្ត្រីរាជការក្រមសីលធម៌នគរបាល និងកងយោធិពលខេមរភូមិន្ទ។ ខុមហ្វ្រែលបានធ្វើការអង្កេតឃើញមានចំនួនមន្ត្រីរាជការស៊ីវិលបានចូលរួមយ៉ាងសកម្មជាមួយគណបក្សនយោបាយ ដែលក្នុងនោះរួមទាំងមន្ត្រីនគរបាល និងយោធាផងដែរ។ ភាគច្រើនសកម្មភាពទាំងនេះ គឺបំរើឲ្យគណបក្សកាន់អំណាច ហើយប្រឆាំងទៅនឹងគណបក្សមិនកាន់អំណាច។ មន្ត្រីរាជការទាំងនោះច្រើនជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា និងចូលរួមយ៉ាងសកម្មភាពនៅក្នុងសកម្មភាពនយោបាយនៃគណបក្សនោះ។ ឧទាហរណ៍ការចូលរួមកិច្ចប្រជុំគណបក្សប្រជាជនកម្ពុជា ការចែកអំណោយ និងការសន្យាមួយចំនួនទៅកាន់ប្រជាពលរដ្ឋក្នុងកំឡុងពេលព្រឹត្តការណ៍សាធារណៈ។ ថ្វីបើប្រការ ឬបញ្ញត្តិច្បាប់បច្ចុប្បន្នដែលបានរៀបរាប់ខាងលើបានហាមឃាត់យ៉ាងតឹងរ៉ឹង ចំពោះសកម្មភាពនយោបាយរបស់មន្ត្រីរបស់រដ្ឋ ប៉ុន្តែការអនុវត្ត គឺគាំទ្រយ៉ាងសកម្មចំពោះ គណបក្សប្រជាជនកម្ពុជាដើម្បីនិរន្តរភាព និងពង្រឹងការគាំទ្រផ្នែកនយោបាយ។ លើសពីនេះទៅទៀត សកម្មភាពគណបក្សនេះភាគច្រើនបានប្រព្រឹត្តនៅកំឡុងពេលម៉ោងធ្វើការដែលបានរកឃើញមានចំនួន១២០ករណី (៦០%) ដែលមានតែ៨០ករណី(៤០%) បានធ្វើសកម្មភាពនៅកំឡុងពេលថ្ងៃឈប់សម្រាក។

លើសពីនេះទៅទៀត ខុមហ្វ្រែលបានសង្កេតឃើញថា គណបក្សប្រជាជនកម្ពុជាបានផ្តល់តំណែងក្នុងគណបក្សទៅឲ្យមន្ត្រីរាជការស៊ីវិល ប៉ូលិស និងកងកម្លាំងប្រដាប់អាវុធដែលមានមុខងារសំខាន់ៗ។ ការអង្កេតក៏បានរកឃើញទៀតថា អភិបាលខេត្ត អភិបាលក្រុង/ស្រុក ប្រធានផ្នែករដ្ឋបាលស៊ីវិលរបស់រដ្ឋ និងប្រធាននាយកដ្ឋានកងកម្លាំងប្រដាប់អាវុធ ត្រូវបានរៀបចំមុខងារជាមន្ត្រីរបស់រដ្ឋ និងបានហាមឃោត់ក្នុងការចូលរួមសកម្មភាពនយោបាយនៃគណបក្សណាមួយក៏ដោយ ប៉ុន្តែពួកគេត្រូវបានផ្តល់ដោយគណបក្សប្រជាជនកម្ពុជា ដូចជាប្រធានគណបក្សប្រជាជនកម្ពុជាប្រចាំខេត្ត/ក្រុង/ស្រុក សមាជិកគណៈកម្មាធិការនៅថ្នាក់ខេត្ត/ក្រុង/ស្រុកជាដើម។ ខុមហ្វ្រែលក៏បានរកឃើញទៀតថា មន្ត្រីរាជការដែលមានឋានៈចាប់ពី ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន អគ្គនាយកក៏មានមុខងារជាប្រធាន និងអនុប្រធាននៃគណបក្សប្រជាជនកម្ពុជានៅតាមតំបន់ ដែលពួកគេទទួលខុសត្រូវជាមន្ត្រីរបស់រដ្ឋផងដែរ។ សមាជិកមន្ត្រីរាជការស៊ីវិលផ្សេងទៀត មន្ត្រីនគរបាល មន្ត្រីយោធាបានចូលរួមនៅក្នុងសកម្មភាពគណបក្សដែលមានដូចជាអភិបាលខេត្ត/ក្រុង/ស្រុក អភិបាលរង

ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ មន្ត្រីប៉ូលិស។ ការអង្កេតនេះ គឺរកឃើញថាមន្ត្រីប៉ូលីស និងមន្ត្រីយោធាបានគាំទ្រជាសាធារណៈចំពោះគណបក្សប្រជាជនកម្ពុជា។ ឧទាហរណ៍ លោក ម៉ា ឈឿន ប្រធានរាជបណ្ឌិតសភាកម្ពុជា និងលោក សួន ផល្លា ជាឧត្តមសេនីយទោ បានអំពាវនាវឲ្យប្រជាជនបោះឆ្នោតឲ្យគណបក្សប្រជាជនកម្ពុជា[2]។ គណបក្សប្រជាជនកម្ពុជាច្បាស់ណាស់ បានធ្វើការពង្រីករចនាសម្ព័ន្ធរបស់ខ្លួននៅតាមមន្ត្រីរដ្ឋបាលរបស់រដ្ឋ កងកម្លាំងប៉ូលិសទាហាន។ ខុមហ្វ្រែលក៏បានបន្តរកឃើញ ភាគច្រើនអភិបាលខេត្ត និងអភិបាលស្រុក និងមន្ត្រីសាធារណៈដែលមានតួនាទីខ្ពស់ក៏មានមុខងារក្នុងគណបក្សប្រជាជនកម្ពុជាផងដែរ។ សកម្មភាព និងការប្រព្រឹត្តិទាំងអស់នេះ គឺបានធ្វើផ្ទុយទៅនឹងមាត្រា៣៧នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលហាមសកម្មភាពគណបក្សនយោបាយ។ ក៏ដូចគ្នានេះដែរ មន្ត្រីប៉ូលីស និងកងកម្លាំងប្រដាប់អាវុធដែលចូលរួមសកម្មភាពគណបក្សនយោបាយ គឺប្រព្រឹត្តផ្ទុយទៅនឹងមាត្រា១៥នៃច្បាប់ស្តីពីច្បាប់គណបក្សនយោបាយឆ្នាំ១៩៩៧ ដែលបានកំណត់ទៀតថា*គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធក្នុងស្ថាប័នសាសនា យោធា និងកងកម្លាំងប្រដាប់អាវុធ*។ ចំពោះ២០០ករណី គឺកើតឡើងច្រើនជាងគេក្នុងខេត្តកណ្តាល និងទីក្រុងភ្នំពេញដែលបង្ហាញក្នុងតារាងខាងក្រោម[3]៖

| លេខ | ខេត្ត | ថ្ងៃធ្វើការ | ថ្ងៃឈប់សម្រាក | សរុប |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៥ | ២ | ៧ |
| ២ | បាត់ដំបង | ៣ | ១ | ៤ |
| ៣ | ពោធសាត់ | ២ | ៣ | ៥ |
| ៤ | កំពង់ឆ្នាំង | ៤ | ២ | ៦ |
| ៥ | កណ្តាល | ៣៤ | ២៦ | ៦០ |
| ៦ | ភ្នំពេញ | ២៨ | ៨ | ៣៦ |
| ៧ | តាកែវ | ៥ | ១ | ៦ |
| ៨ | កំពត | ៥ | ១ | ៦ |
| ៩ | កែប | ១ | ២ | ៣ |
| ១០ | ព្រៃវែង | ១ | ៤ | ៥ |
| ១១ | ស្វាយរៀង | ៨ | ៣ | ១១ |
| ១២ | កំពង់ស្ពឺ | ៣ | ២ | ៥ |
| ១៣ | កំពង់ចាម | ១០ | ៨ | ១៨ |
| ១៤ | ក្រចេះ | ២ | ០ | ២ |
| ១៥ | មណ្ឌលគិរី | ០ | ១ | ១ |

[2] លោក ម៉ា ឈឿន បានធ្វើការអំពាវនាវនៅថ្ងៃទី ២ ខែមករា ឆ្នាំ ២០១២ នៅកំពង់ចាម នៅពេលដែលលោកបានចូលរួមខួបទី ៣៣ នៃទិវាជ័យជំនះ ៧មករា នៅឯស្នាក់ការគណបក្សបក្សប្រជាជនកម្ពុជាខេត្តកំពង់ចាម។ លោក សួន ផល្លា បានធ្វើការអំពាវនាវដល់អ្នកបោះឆ្នោត នៅថ្ងៃទី ១៥ តុលា ២០១២ នៅពេលលោកបានចែកអំណោយដល់វត្តសុវណ្ណគីរីជើងនៅខេត្តកំពង់ចាម។

[3] សូមមើលតារាងលំអិត នៃករណីទាំងអស់នៅឧបសម្ព័ន្ធទី ២ នៃការសិក្សានេះ។ ខុមហ្វ្រែលមិនទាន់បានទទួលព័ត៌មាននៅក្នុងកំឡុងពេលសង្កេត (ស្ទឹងត្រែង រតនគិរី ព្រះសីហនុ និងកោះកុង)។

| | | | | |
|---|---|---|---|---|
| ១៦ | ព្រះវិហារ | ០ | ២ | ២ |
| ១៧ | ឧត្តរមានជ័យ | ១ | ០ | ១ |
| ១៨ | សៀមរាប | ៥ | ១ | ៦ |
| ១៩ | កំពង់ធំ | ៣ | ១១ | ១៤ |
| ២០ | ប៉ៃលិន | ០ | ២ | ២ |
| **Total** | | ១២០ | ៨០ | ២០០ |

### ៤.១.២ ការប្រើប្រាស់មិនត្រឹមត្រូវកន្លែងសាធារណៈ

អំឡុងពេលខុមហ្វ្រែលធ្វើការសង្កេតឃើញថា ការប្រើប្រាស់ទីធ្លាសាធារណៈត្រូវបានត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជា (ការសង្កេតកន្លងមកត្រូវបានបង្ហាញដូចគ្នាដែរ[4])។

គណបក្សប្រជាជនកម្ពុជាត្រូវបានដឹងថា មានលទ្ធភាពប្រើប្រាស់ទីធ្លាសាធារណៈដើម្បីធ្វើសកម្មភាពឃោសនា និងសកម្មភាពគណបក្សនយោបាយច្រើនជាងគណបក្សនយោបាយផ្សេងទៀត ទោះបីជាច្បាប់បោះឆ្នោតបានផ្តល់ឱកាសស្មើគ្នាសំរាប់ការប្រើប្រាស់ទីធ្លាសាធារណៈ (លើកលែងតែក្នុងអគាររដ្ឋ)។ ពិតណាស់គណបក្សប្រជាជនកម្ពុជា បានរំលោភបំពានទៅលើមុខតំណែងមន្ត្រីរបស់រដ្ឋ ដែលធ្វើឲ្យប៉ះពាល់ដល់គណបក្សនយោបាយផ្សេងទៀតផងដែរ។ ខុមហ្វ្រែលរកឃើញថាជារឿយៗនៅតាមទីកន្លែងធំៗមួយចំនួន ដូចជាសួនច្បារ ផ្លូវជាតិ និងមហាវិថីធំៗមួយចំនួន គណបក្សនយោបាយដទៃទៀតដែលមិនមែនគណបក្សប្រជាជនកម្ពុជាតែងតែរងការគំរាមកំហែង និងមិនត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញស្លាកគណបក្ស និងរូបភាពថ្នាក់ដឹកនាំ។ កន្លែងសំរាប់សកម្មភាពនយោបាយ ត្រូវបានបង្កភាពងាយស្រួលដល់គណបក្សប្រជាជនកម្ពុជា ជាជាងគណបក្សផ្សេងទៀត។ ឧទាហរណ៍ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ គណបក្សសមរង្ស៊ីរៀបចំលើកផ្លាកគណបក្សនៅឯសាលាខេត្តប៉ៃលិន ដែលនៅក្បែរស្លាកគណបក្សប្រជាជនកម្ពុជាផងដែរនោះ ប៉ុន្តែត្រូវបានប៉ូលិសធ្វើការរារាំង និងរឹបអូស។

### ៤.១.៣ ភាពមិនត្រឹមត្រូវនៃប្រព័ន្ធផ្សព្វផ្សាយសាធារណៈ

ទន្ទឹមនឹងនេះដែរ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា។ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដូចជា ទូរទស្សន៍ជាតិកម្ពុជា(ទទក) និងអាអឹម៩១៨ បានផ្តល់ឱកាសដល់គណបក្សប្រជាជនកម្ពុជា ហើយបន្តគ្មានភាពសមធម៌សំរាប់គណបក្សផ្សេងទៀត ក្នុងងប្រព័ន្ធផ្សព្វផ្សាយរដ្ឋនេះ[5]។ បើទោះជាមានគោលការណ៍សមធម៌សំរាប់គ្រប់គណបក្សនយោបាយយ៉ាងណាក៏ដោយ ក្រសួងពត៌មាន និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនទាន់មានវិធានការច្បាស់ ដើម្បីធានាសមធម៌ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរដ្ឋប្រតិទិនរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ប៉ុន្តែវាជាការព្រួយបារម្ភសំរាប់គ្រប់គណបក្សនយោបាយទាំងអស់ក្នុងកំឡុងពេលបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជា បន្តសកម្មភាពផ្សពផ្សាយសកម្មភាពខ្លួនដែលរួមបញ្ចូលការផ្សព្វផ្សាយអំពីកិច្ចប្រជុំគណបក្ស យុទ្ធនាការ និងពិធីចុះចែកអំណោយផ្សេងៗ។ សកម្មភាពខាងលើនេះ ត្រូវបានខុមហ្វ្រែលអង្កេតនៅតាមវិទ្យុ និងទូរទស្សន៍ជាតិដែលធនធានរបស់រដ្ឋ រួមមានទាំងសម្ភារៈ និងធនធានមនុស្សរបស់រដ្ឋត្រូវបានប្រើប្រាស់ ដើម្បីជាគុណ

[4] សូមមើលរបាយការណ៍ខុមហ្វ្រែលៈ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៨-របាយការណ៍វាយតម្លៃ ភ្នំពេញ ២០០៨

[5] សូមមើលរបាយការណ៍ខុមហ្វ្រែលៈ ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់ ២០១១ ភ្នំពេញ ខែមិនា ២០១២

ប្រយោជន៍សម្រាប់គណបក្សប្រជាជនកម្ពុជា។ ការផ្សព្វផ្សាយពីការចែកអំណោយ បានផ្សាយក្នុងទទូរទស្សន៍ និងវិទ្យុជាតិ អារអឹម៩១៨ គឺថែមទាំងបង្ហាញយ៉ាងច្បាស់ ពីការប្រព្រឹត្តខុសនឹងវិជ្ជាជីវៈរបស់មន្ត្រីរាជការស៊ីវិលដែលបានសង្កេតដោយខុមហ្វ្រែល។ ឧទាហរណ៍ ទូរទស្សន៍ជាតិកម្ពុជាធ្លាប់បានផ្សាយព័ត៌មាននៃពិធីចែកអំណោយរបស់គណបក្សប្រជាជនកម្ពុជា ស្របពេលដែលអភិបាលស្រុកបាកានចូលរួម។ សំរាប់វិទ្យុជាតិអារអឹម៩១៨ ខុមហ្វ្រែលបានសង្កេតឃើញការប្រជុំរវាងអភិបាលស្រុកបាគង និងសមាជិកគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា។ របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយមួយ ពីការចុះចែកអំណោយរបស់មន្ត្រីយោធាសំរាប់យុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពតផងដែរ។

## ៤.២. ការស្ទាបស្ទង់ទស្សនៈម្ចាស់ឆ្នោតរបស់អង្គការខុមហ្វ្រែល

ខុមហ្វ្រែលបានពង្រាយអ្នកសង្កេតការណ៍ចំនួន២៣១នាក់ ដើម្បីធ្វើស្ទាបស្ទង់ជាមួយអ្នកដែលមានសិទ្ធិបោះឆ្នោតចំនួន៨,៦៧២នាក់ ទៅលើការប្រើប្រាស់ធនធានរដ្ឋ ដើម្បីផលប្រយោជន៍គណបក្សនយោបាយ។ ក្នុងនោះបានធ្វើការស្ទាបស្ទង់ចំនួន៦០% ជាស្ត្រី និង៤០% ជាបុរស។ ២៨%នៃអ្នកផ្តល់សម្ភាសន៍មានអាយុចន្លោះពី១៨ ទៅ៣០ឆ្នាំ។ ការចុះស្ទាបស្ទង់មតិម្ចាស់ឆ្នោតនេះ ត្រូវធ្វើឡើងនៅខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១១ នៅទូទាំង ខេត្ត/រាជធានី អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានសួរ ប្រសិនបើពួកគេធ្លាប់បានឃើញការប្រើប្រាស់ធនធានរដ្ឋដើម្បីផលប្រយោជន៍នយោបាយដែលមន្ត្រីរាជការស៊ីវិល មន្ត្រីយោធា និងកងកម្លាំងប្រដាប់អាវុធចូលរួមនៅក្នុងសកម្មភាពគណបក្សនយោបាយ។

សំណួរដំបូងដែលខុមហ្វ្រែលលើកឡើង ដើម្បីសួរទៅអ្នកបោះឆ្នោត ប្រសិនបើពួកគេធ្លាប់សង្កេតមានមន្ត្រីរាជការស៊ីវិល សមាជិកកងកម្លាំងប្រដាប់អាវុធ ចូលរួមក្នុងពិធីចែកអំណោយបម្រើឲ្យគណបក្សនយោបាយ និងចូលរួមយ៉ាងសកម្មក្នុងការចែកអំណោយរបស់គណបក្សចាប់តាំងពីឆ្នាំ២០០៩មក។ ដោយយោងតាមរូបភាពទី១ បានបង្ហាញថា ១៦,៤% នៃអ្នកផ្តល់ចម្លើយធ្លាប់ឃើញមន្ត្រីរាជការស៊ីវិល ឬកងកម្លាំងប្រដាប់អាវុធ (ប៉ូលិស និងយោធា) ចូលរួមសកម្មភាពយ៉ាងសកម្មនៅក្នុងព្រឹត្តិការណ៍នេះ។ ហើយនេះ គឺជាសញ្ញាដែលចង្អុលបង្ហាញថាមានចំនួនមន្ត្រីរាជការស៊ីវិលយ៉ាងច្រើនចូលរួមក្នុងសកម្មភាពគណបក្សនយោបាយ។

**រូបភាពទី១៖ តាំងពីឆ្នាំ២០០៩ មកដល់បច្ចុប្បន្ន តើអ្នកធ្លាប់បានឃើញមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ (ប៉ូលិសទាហាន ប៉េអឹម កងអង្គរក្ស) ចូលរួមចែកអំណោយ ឬចូលរួមសកម្មភាពនានារបស់គណបក្សនយោបាយណាមួយដែរឬទេ?**




សំណួរទី២ ត្រូវបានសួរថា ធ្លាប់បានឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅក្នុងពិធីចែកអំណោយនេះដែរឬទេ។ រូប

ភាពទី២ បង្ហាញថា ៨,៣% នៃអ្នកផ្ដល់ចម្លើយធ្លាប់ឃើញឡាន ម៉ូតូមានស្លាកលេខរាជការ រដ្ឋ នគរបាល ឬខេមរភូមិន្ទ ចូលរួមចែកអំណោយ ឬចូលរួមសកម្មភាពនានា របស់គណបក្សនយោបាយណាមួយ។ ដូចនេះ ទង្វើទាំងនេះ គឺផ្ទុយពីច្បាប់ដែលបានហាមប្រើធនធានរដ្ឋសំរាប់ប្រយោជន៍គណបក្សនយោបាយ បើបន្ថែមទៅលើអ្វីដែលខុមហ្វ្រែលបានរកឃើញលើការប្រើប្រាស់ធនធានរដ្ឋចំនួននេះ អាចមានច្រើនជាងអ្វីដែលខុមហ្វ្រែលបានធ្វើការសង្កេតដោយផ្ទាល់។ (សូមមើលរូបភាពទី ៩ និង១០)

**រូបភាពទី ២៖ ចាប់តាំងពីឆ្នាំ ២០០៩ មកដល់បច្ចុប្បន្ន តើអ្នកធ្លាប់ឃើញ ឡាន ម៉ូតូមានស្លាកលេខ រាជការ រដ្ឋ នគរបាល ឬ ខេមរភូមិន្ទ ចូលរួមសកម្មភាពរបស់គណបក្ស ?**




សំណួរទី៣ បានសួរថាធ្លាប់បានទទួលអំណោយពីគណបក្សនយោបាយ ឬក៏ធ្លាប់បានចូលរួមក្នុងពិធីចែកអំណោយ។ រូបភាពទី៣ បានបង្ហាញថា មានអ្នកផ្ដល់ចម្លើយ២៣,៤% ធ្លាប់បានទទួលអំណោយ និងចូលរួមក្នុងពិធីចែកអំណោយរបស់គណបក្សចាប់តាំងពីឆ្នាំ២០០៩មក។ នេះបានសេចក្ដីថា ការចុះចែកអំណោយនេះគឺជាធាតុផ្សំដ៏ចាំបាច់នៅក្នុងយុទ្ធសាស្ត្រឃោសនានៃគណបក្សនយោបាយបច្ចុប្បន្ន។

**រូបភាពទី ៣៖ ចាប់តាំងពីឆ្នាំ ២០០៩ មក តើអ្នកធ្លាប់ទៅចូលរួមទទួលអំណោយ ឬបានទទួលអំណោយ ពីគណបក្សដែរឬទេ?**



ខុមហ្វ្រែលបានធ្វើការសម្ភាសន៍ ថាតើនរណាខ្លះជាអ្នកចូលរួមចែកអំណោយរបស់គណបក្ស។ រូបភាពទី៤ បានបង្ហាញថា ចំនួន ៣៤,១% នៃអ្នកទទួលអំណោយ ឬចូលរួមក្នុងការទទួលអំណោយបានឃើញមេភូមិចុះចែកអំណោយ និងចូលរួមក្នុងពិធីនោះ ខណៈពេលដែលមាន១០,៥% នៃអ្នកទទួលអំណោយ ឃើញសមាជិកគណបក្សនយោបាយចែក ឬចូលរួមក្នុងពិធីនោះ។ មន្ត្រីរាជការស៊ីវិល មន្ត្រីយោធា និងមន្ត្រីប៉ូលិសចូលរួមក្នុងពិធីចែកអំណោយនេះផងដែរ។ អ្នកដែលបានទទួលអំណោយបានរាយការណ៍ថា មាន១,៤% ប៉ូលិស១,៣% មន្ត្រីរាជការស៊ីវិល និង១,១% មន្ត្រីស្ថាប័នព្រមទាំង ០,៩% ទាហាន។ ថ្វីបើចំនួននេះវាតិចតួចក៏ដោយ តែបើយោងទៅតាមច្បាប់ គឺមិនត្រូវអនុញ្ញាតឲ្យមានការចូលរួមសកម្មភាពបែបនេះឡើយ។

**រូបភាពទី ៤៖ បើធ្លាប់បានទទួលអំណោយពីគណបក្ស តើអ្នកណាខ្លះ (តួនាទី) ជាអ្នកផ្ដល់ ឬបានចូលរួមក្នុងកម្មវិធីផ្ដល់អំណោយដល់អ្នក?**




ខុមហ្វ្រែលបានធ្វើការសួរទៅលើសំណួរទី៥ ពីទីកន្លែងដែលគណបក្សធ្វើការផ្ដល់អំណោយ។ តាមរូបភាពទី៥នេះបង្ហាញថា ក្នុងចំណោមអ្នកផ្ដល់ចម្លើយដែលបានទទួលអំណោយ មានចំនួន៣១,៦% បានទទួលអំណោយនៅក្នុងវត្ត ១៧,៦% នៅកន្លែងឯកជន និង១៥%ទៀតនៅទីស្នាក់ការគណបក្ស។ ទោះជាយ៉ាងណា អាគារ និងទីកន្លែងសាធារណៈត្រូវបានប្រើប្រាស់។ ចំណែក១៤,៥% បានធ្វើនៅក្នុងសាលារៀន១២,៨% នៅឯឃុំសង្កាត់ និង១,៥%នៅកន្លែងរដ្ឋ។ ដូច្នេះនេះ គឺជាការប្រព្រឹត្តិផ្ទុយនឹងច្បាប់ដែលហាមមិនឲ្យប្រើប្រាស់ធនធានរដ្ឋជាប្រយោជន៍គណបក្សនយោបាយ ជាពិសេសនៅក្នុងបទបញ្ញា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានបង្ហាញនៅក្នុងរបាយការណ៍នេះផងដែរ។

**រូបភាពទី ៥៖ តើអ្នកធ្លាប់ទទួលអំណោយនៅកន្លែងណាខ្លះ?**




ខុមហ្វ្រែលបានសួរទៅអ្នកសម្ភាសន៍ ដែលបានចូលរួមក្នុងពិធីចែកអំណោយ ប្រសិនបើពួកគេធ្លាប់បានឃើញឡាន ម៉ូតូ ដែលមានស្លាកលេខរាជការ រដ្ឋ នៅឯទីកន្លែងចែកអំណោយ។ រូបភាពទី៦ បង្ហាញថា ក្នុងចំណោមអ្នកផ្តល់ចម្លើយ ដែលបានទទួលអំណោយ៤៦,៦%និយាយថា ពួកគាត់មិនបានចាប់អារម្មណ៍ថា មានយានជំនិះដែលមានស្លាកលេខរដ្ឋ នៅកន្លែងចែកអំណោយ ប៉ុន្តែ២០,៣% បានឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅកន្លែងចែកអំណោយ។ នេះក៏ជាភស្តុតាងមួយសំរាប់ការប្រើប្រាស់ធនធានរដ្ឋ និងបញ្ជាក់ពីការសង្កេតរបស់ខុមហ្វ្រែល។ ចំនួននេះគឺខ្ពស់ និងច្រើនជាងនៅក្នុងរូបភាពទី២ ដែលម្ចាស់ឆ្នោតត្រូវបានសួរពីការទទួលអំណោយ និងចូលរួមសកម្មភាពរបស់គណបក្ស។

**រូបភាពទី ៦៖ តើអ្នកធ្លាប់ឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅក្នុងពីធីរបស់គណបក្សដែរឬទេ?**



បន្ទាប់មកសំណួរដែលខុមហ្វ្រែលបានសួរ ថាតើអ្នកផ្តល់បទសម្ភាសន៍ បានចូលរួមការប្រជុំរបស់គណបក្សនយោបាយតាំងពីឆ្នាំ២០០៩។ រូបភាពទី៧ បានបង្ហាញថា ត្រឹមតែ១៥,៨% នៃអ្នកផ្តល់បទសម្ភាសន៍បានចូលរួមការប្រជុំរបស់គណបក្សនយោបាយនៅក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះ។ ៨៤,២% នៃអ្នកផ្តល់ចម្លើយ ពួកគេមិនដែលបានចូលរួមប្រជុំរបស់គណបក្សនយោបាយទេ។ សំណួរនេះត្រូវបានសួរដើម្បីបញ្ជាក់ថាតើ អ្នកបោះឆ្នោតដែលបានចូលរួមប្រជុំរបស់គណបក្សនយោបាយបានធ្លាប់ឃើញមាន ការប្រើប្រាស់ធនធានរបស់រដ្ឋ ឬសម្ភារៈរដ្ឋនៅក្នុងការប្រជុំនេះឬទេ។

**រូបភាពទី ៧៖ តើអ្នកធ្លាប់ចូលរួមការប្រជុំរបស់គណបក្សនយោបាយដែរឬទេ តាំងពីឆ្នាំ ២០០៩ មក**




សំណួរបន្ទាប់ត្រូវបានសួរថា នរណាខ្លះបានចូលរួមការប្រជុំរបស់គណបក្សនោះ។ រូបភាពទី៨ បានបង្ហាញថា ក្នុងចំណោមអ្នកដែលបានចូលរួមប្រជុំ ២៩,២% បានធ្លាប់ឃើញមេភូមិ ក្នុងកំឡុងពេលនៃការប្រជុំរបស់គណបក្សនយោបាយ ព្រមទាំងមន្ត្រីរបស់រដ្ឋដែលអ្នកទាំងនេះ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងពិធីនេះទេ។ ផ្អែកទៅលើអ្នកផ្តល់បទសម្ភាសន៍ដែលបានចូលរួមប្រជុំរបស់គណបក្ស ៣,៤% បានឃើញប៉ូលិស ១% បានឃើញទាហាន ២% បានឃើញមន្ត្រីរាជការស៊ីវិល និង១,៨% បានឃើញមន្ត្រីក្រសួង ឬស្ថាប័ន។

**រូបភាពទី ៨ ៖ តើមានអ្នកណាខ្លះចូលរួមការប្រជុំរបស់គណបក្ស?**



សំណួរបន្ទាប់ខុមហ្វ្រែលបានសួរពីទីកន្លែងប្រជុំ ថាតើបានធ្វើនៅកន្លែងណាខ្លះ។ រូបភាពទី៩ បានបង្ហាញថា ក្នុងចំណោមអ្នកដែលបានចូលរួមប្រជុំ ២៧,៤% បានលើកឡើងថាការប្រជុំបានធ្វើនៅទីវត្តអារាម។ ២៦% បានធ្វើនៅស្នាក់ការគណបក្ស ១៥%នៅឯកន្លែងឯកជន ១៣% នៅការិយាល័យឃុំសង្កាត់ ១១,២% នៅសាលារៀន និង១,៤% នៅឯអាគាររបស់រដ្ឋ។ ករណីក្រោយនេះគឺជាការដ៏គួរឲ្យសង្ស័យថា នេះគឺជាការប្រឆាំងនឹងច្បាប់ដែលបញ្ជាក់យ៉ាងច្បាស់ថា អាគារ និងទីធ្លារបស់រដ្ឋមិនអាចប្រើប្រាស់សំរាប់ប្រយោជន៍គណបក្សបានឡើយ។

**រូបភាពទី ៩៖ តើការប្រជុំរបស់គណបក្សធ្វើនៅឯណា?**




សំណួរបន្ទាប់ខុមហ្វ្រែលបានសួរអ្នកផ្តល់បទសម្ភាសន៍ ដែលបានចូលរួមប្រជុំរបស់គណបក្សនយោបាយ ពីការបានឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅកំឡុងពេលកិច្ចប្រជុំរបស់គណបក្ស។ រូបភាពទី១០ បានបង្ហាញថា ២៥,២% (អ្នកដែលបានចាប់អារម្មណ៍) បានលើកឡើងថា ពួកគេធ្លាប់ឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅក្នុងការប្រជុំនេះ។ នេះអាចបង្ហាញពីភាគរយដ៏ខ្ពស់ដែលជាប់ពាក់ព័ន្ធថា គណបក្សនយោបាយប្រាកដជាបានទទួលប្រយោជន៍ពីការប្រើប្រាស់ធនធានរបស់រដ្ឋសំរាប់សកម្មភាពរបស់ពួកគេ ដែលបន្ថែមទៅនឹងការរកឃើញរបស់ខុមហ្វ្រែលថា ករណីនេះគឺច្រើនជាងខុមហ្វ្រែលសង្កេតដោយផ្ទាល់ទៅទៀត។ (មើលរូបភាពទី ២)

**រូបភាពទី ១០៖ តើអ្នកធ្លាប់ឃើញយានជំនិះដែលមានស្លាកលេខរដ្ឋនៅក្នុងការប្រជុំរបស់គណបក្សនយោបាយដែរឬទេ?**




## ៥. សន្និដ្ឋាន

ការសិក្សាបង្ហាញថា ការប្រើប្រាស់ធនធានរបស់រដ្ឋ រួមបញ្ចូលរបស់មន្ត្រីរាជការស៊ីវិល និងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលដែលធ្វើសកម្មភាពសំរាប់គណបក្សនយោបាយ។ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ គឺវាក្លាយជារឿងធម្មតា នៅក្នុងដំណើរការនយោបាយនៅក្នុងប្រទេសកម្ពុជា តែវាផ្ទុយទៅនឹងបទបញ្ញត្តិហាមឃាត់សកម្មភាពទាំងនេះ។ ប្រាកដណាស់គណបក្សប្រជាជនកម្ពុជា (CPP) គឺជាប់ទាក់ទងយ៉ាងខ្លាំងបំផុតទៅនឹងសកម្មភាព ឬការអនុវត្តន៍ដែលគួររចោទសួរ ពីព្រោះថាមន្ត្រីជាន់ខ្ពស់គណបក្សនេះ ត្រូវបានរៀបចំលក្ខណៈជាប្រព័ន្ធចេញពីរដ្ឋបាលស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងប៉ូលិស ដើម្បីបន្តការត្រួតត្រាអំណាចបច្ចុប្បន្ននៅក្នុង រដ្ឋាភិបាល។ ករណីដែលបានសង្កេត និងវិភាគនៅក្នុងការសិក្សានេះដោយខុមហ្វ្រែល បានបង្ហាញដែលមិនអាចប្រកែកបានថា មន្ត្រីរដ្ឋបាលស៊ីវិល សមាជិកកងកម្លាំងប្រដាប់អាវុធ និងសមាជិករបស់គណបក្សប្រជាជនកម្ពុជាមានករណីមិនគោរពទៅលើបញ្ញត្តិនៃច្បាប់ និងក្រមសីលធម៌ដែលបានហាមឃាត់មន្ត្រីរបស់រដ្ឋាភិបាលចូលរួមក្នុងសកម្មភាពឃោសនានយោបាយសំរាប់គណបក្ស។

ការសង្កេតដោយផ្ទាល់របស់ខុមហ្វ្រែល និងការវិភាគលើប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានបង្ហាញលទ្ធផលថា ការប្រើប្រាស់ធនធានរបស់រដ្ឋសំរាប់គណបក្សនយោបាយមួយ គឺបានកើតឡើងយ៉ាងច្រើននៅពេលបច្ចុប្បន្ន។ ការសង្កេតស្ទាបស្ទង់ទៅលើអ្នកបោះឆ្នោតក៏បានបញ្ជាក់ និងបន្ថែមទៅលើការសង្កេតនាពេលខាងមុខជាមួយនឹងភស្តុតាង ដែលអ្នកបោះឆ្នោតខ្លួនឯងមានការសង្កេតទៅលើមន្ត្រីរបស់រដ្ឋចូលរួមសកម្មភាពរបស់គណបក្សនយោបាយ និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋសំរាប់ផលប្រយោជន៍គណបក្សនយោបាយ។ ឧបសម្ព័ន្ធនៃការសិក្សានេះ ត្រូវបានបញ្ជាក់ពីការសង្កេតជាមួយនឹងឧទាហរណ៍យ៉ាងច្រើន។ ការប្រើប្រាស់ធនធានរបស់រដ្ឋសំរាប់គោលបំណង ឬផលប្រយោជន៍គណបក្សនយោបាយនៅតែជាបញ្ហាដ៏គួរឲ្យព្រួយបារម្ភ ពីព្រោះថាវាបានរួមចំណែក ឬបង្ហាញនូវភាពមិនស្មើគ្នាសំរាប់ទីលានប្រកួតប្រជែងរបស់គណបក្សនយោបាយនិងក៏បន្ថែមការមន្ទិលថាតើការបោះឆ្នោត
ស្របតាមគោលការណ៍ល្អសេរី និងយុត្តិធម៌ស្របតាមដែរឬទេ។

ម្យ៉ាងវិញទៀត ការរំលោភលើធនធានរដ្ឋ គឺមិនត្រឹមតែជាសកម្មភាពខុសច្បាប់នោះទេ ប៉ុន្តែវាអាចត្រូវបានគេមើលរំលង ឬដាក់ទៅម្ខាងដោយមិនយកចិត្តទុកដាក់។ ការអនុវត្តន៍នេះ អាចបង្កើតបរិយាកាសឲ្យមានភាព ភ័យខ្លាច និងគំរាមកំហែងដល់ប្រជាពលរដ្ឋ ជាពិសេសសំរាប់ប្រទេសបន្ទាប់ពីមានសង្គ្រាមស៊ីវិល ដែលកំពុងអន្តរកាលទៅរកប្រជាធិបតេយ្យ និងនៅតែមានការចងចាំពីការភ័យខ្លាច និងអំពើហិង្សាខាងនយោបាយពីអតីតកាល។ ប្រជាពលរដ្ឋបានជួបបញ្ហាជាមួយនឹងមន្ត្រីរបស់រដ្ឋ នគរបាល ឬសមាជិកកងយោធពលខេមភូមិន្ទដែលបានផ្តល់ការណែនាំទៅប្រជាពលរដ្ឋឲ្យគាំទ្រគណ

បក្សនយោបាយ។ អ្នកបោះឆ្នោតក៏នៅក្រោមសម្ពាធចំណែកមន្ត្រីរដ្ឋបាលស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងនគរបាលខ្លះនេះអាចមានអារម្មណ៍ថា ត្រូវបានបង្ខាប់បញ្ហាក្នុងការចូលរួមសកម្មភាពគណបក្សនយោបាយដើម្បីការពារតំណែង។ សកម្មភាពនេះ អាចធ្វើឲ្យសេរីភាពនៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋមានកំរិត ដោយសារតែប្រជាពលរដ្ឋមានអារម្មណ៍ភ័យខ្លាចនៅពេលដែល ពួកគេមិនទាន់ច្បាស់ថា មន្ត្រីរដ្ឋបាលស៊ីវិលនឹងមានភាពអព្យាក្រឹត្យឬអត់ នៅពេលដែលប្រជាពលរដ្ឋមានសញ្ញាណណាមួយដែលបង្ហាញពីការពេញចិត្តចំពោះគណបក្សនយោបាយផ្សេង។

ផ្ទុយពីនេះ ខុមហ្វ្រែលបានផ្ដល់អនុសាសន៍ដើម្បីធ្វើការសង្កត់ធ្ងន់ទៅនឹងការអនុវត្តន៍ឲ្យមានប្រសិទ្ធិភាពនូវច្បាប់ដែលមានពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានរបស់រដ្ឋសំរាប់ផលប្រយោជន៍គណបក្សនយោបាយ។ ច្បាស់ណាស់ប្រការរបស់បទបញ្ញា និងនីតិវិធីរបស់គណៈកម្មាធិការរៀបចំការបោះឆ្នោត (គជប) ហាក់ដូចជាផ្ទុយនឹងមាត្រានៃច្បាប់ដែលហាមឃាត់មន្ត្រីរបស់រដ្ឋក្នុងសកម្មភាពគណបក្សនយោបាយ។ តាមរយៈនេះមានន័យថា ព្រះរាជាណាចក្រកម្ពុជាមានជំរើសគោលនយោបាយពីរផ្សេងគ្នា។ ថាតើ វាអនុញ្ញាតឲ្យការប្រើប្រាស់ធនធានរបស់រដ្ឋដែលទាក់ទងទៅនឹងទីធ្លាសាធារណៈ ទ្រព្យសម្បត្តិប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងហិរញ្ញវត្ថុសំរាប់គណបក្សនយោបាយ ដែលធានាគោលការណ៍សមធម៌សំរាប់គ្រប់គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភា (អនុវត្តសំរាប់ការអនុវត្តន៍ដ៏ល្អបំផុតលក្ខណៈអន្តរជាតិ) ឬបន្តហាមឃាត់ការប្រើប្រាស់ធនធានរដ្ឋដោយការដាក់ចេញនូវវិធានការជាក់លាក់ដើម្បីកែប្រែមាត្រា ឬប្រការបច្ចុប្បន្ន។ ឧទាហរណ៍ ច្បាប់ស្ដីពីហិរញ្ញវត្ថុគណបក្សនយោបាយគួរតែត្រូវបានអនុម័ត។ ការហាមឃាត់បច្ចុប្បន្នចំពោះសកម្មភាពគណបក្សនយោបាយដោយអង្គការ និងសមាគម (លើកលែងអង្គការអន្តរជាតិ) ហាក់ដូចជាមាន ការកំណត់សិទ្ធិនយោបាយដែលហាក់ដូចជាមានស្តង់ដារពីរជាមួយមន្ត្រីរដ្ឋ។ ហេតុដូច្នេះ ទាំងនេះគួរតែត្រូវបានធ្វើការពិចារណាឡើងវិញ។

ខុមហ្វ្រែលថែមទាំងសង្ឃឹមថា ការសិក្សានេះនឹងធ្វើឲ្យមានការយល់ដឹងជាសាធារណៈនូវបញ្ហាដែលបានលើកឡើង និងជួយបង្កើនឲ្យមានការគោរពសំរាប់ការហាមឃាត់នៃច្បាប់សំរាប់ការប្រើប្រាស់ធនធានរដ្ឋសំរាប់គោលបំណងគណបក្សនយោបាយ។ ខុមហ្វ្រែលក៏សង្ឃឹមទៀតថា ព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គជប) នឹងធ្វើសកម្មភាព ដើម្បីទប់ស្កាត់ការប្រើប្រាស់ធនធានរបស់រដ្ឋសំរាប់ប្រយោជន៍គណបក្សនយោបាយ។ វិធានការអប់រំអាចជាឧទាហរណ៍ទៅលើគោលនយោបាយដែលមានប្រសិទ្ធិភាព ដើម្បីលើកទឹកចិត្តមន្ត្រីរបស់រដ្ឋបញ្ឈប់ពីការធ្វើខុសនឹងវិជ្ជាជីវៈ។ គណបក្សប្រជាជនកម្ពុជា ពេលនេះអាចចាប់ផ្ដើមធ្វើការកែប្រែគោលនយោបាយបច្ចុប្បន្ន ដែលលើកទឹកចិត្តមន្ត្រីរបស់រដ្ឋចូលរួមក្នុងសកម្មភាពគណបក្សខ្លួនជំនួសការផ្ដួចផ្ដើមកំណែទម្រង់ ដែលគាំទ្រគណបក្សនយោបាយក្រោមលក្ខខណ្ឌសំរាប់ទីលានប្រកួតប្រជែងផ្នែកនយោបាយដែលធ្វើឲ្យការបោះឆ្នោតសេរី និងយុត្តិធម៌ ផ្អែកលើគោលការណ៍អនុវត្តកំរិតជាតិ និងអន្តរជាតិ។

## ឧបសម្ព័ន្ធ ១៖ វិធីសាស្ត្រនៃការសង្កេត

### ១. អ្វីខ្លះដែលត្រូវសង្កេត

**ក. មន្ត្រីរាជការ និងបុគ្គលិករដ្ឋទាំងអស់ (បុគ្គលិករដ្ឋមិនរាប់បញ្ចូលសមាជិករដ្ឋសភា ព្រឹទ្ធសភានិងគណៈរដ្ឋមន្ត្រី និងមន្ត្រីជាប់ឆ្នោតតាមបែបសកល ឬអសកលផ្សេងទៀតនោះទេ)៖** ការចូលរួមនៅក្នុងសកម្មភាពគណបក្សនយោបាយដូចជា សមាជិកដឹកនាំរបស់គណបក្ស ចូលរួមឃោសនាផ្សព្វផ្សាយរបស់គណបក្ស ចូលរួមសកម្មភាពចែកអំណោយរបស់គណបក្ស និងការចូលរួមជួយរៀបចំសកម្មភាពនានារបស់គណបក្ស និងពង្រឹង ឬបង្កើតបណ្តាញឲ្យសាខាបក្ស ។

***ការណែនាំ៖*** *អ្នកសង្កេតការណ៍ត្រូវពិនិត្យ និងមើលថា តើក្នុងកម្មវិធីរបស់គណបក្សនយោបាយដែលកំពុងដំណើរការ តើមានបុគ្គលិករដ្ឋ មន្ត្រីរាជការដូចជាអភិបាលខេត្ត ស្រុក ប្រធានមន្ទីរ ឬបុគ្គលិកចូលរួមនៅក្នុងកម្មវិធីនោះខណ្ឌ/ដែរឬទេ។*

*អ្នកសង្កេតការណ៍អាចដឹងដោយអ្នកសង្កេតការណ៍ស្គាល់បុគ្គលនោះដែលជាបុគ្គលិករដ្ឋ ឬតាមរយៈការប្រកាសផ្សាយនៅក្នុងកម្មវិធី ឬអត្តសញ្ញាណផ្សេងៗ។*

**ខ. ទីកន្លែងរបស់រដ្ឋដូចជា៖** ទីកន្លែងរបស់រដ្ឋគឺសម្តៅលើទីតាំងរបស់រដ្ឋដូចជាបរិវេណ ឬអាគាររបស់ក្រសួង មន្ទីរ សាលារាជធានី/ខេត្ត សាលាស្រុក/ខ័ណ្ឌ/ក្រុង សាលាឃុំ និងទីកន្លែងផ្សេងទៀតដែលជាកម្មសិទ្ធិរបស់រដ្ឋត្រូវបាន គណបក្សនយោបាយយកមកធ្វើសកម្មភាពដូចជា ប្រជុំ ចែកអំណោយ ឬឃោសនា ឬផ្សព្វផ្សាយសកម្មភាពផ្សេងទៀតរបស់គណបក្សដូចជាការបិទរូបស្លាកសញ្ញា ឬកម្មវិធីនយោបាយរបស់គណបក្សនោះជាដើម ។ល។

***ការណែនាំ៖*** *អ្នកសង្កេតការណ៍ត្រូវមើលទីកន្លែងផ្សេងរបស់រដ្ឋ។ ហើយត្រួតពិនិត្យមើលថា តើទីកន្លែងនោះមានការបិទឃោសនារបស់គណបក្សនយោបាយណាដែរ ឬទេ។ បើសិនជាមានសកម្មភាពនៅក្នុងទីកន្លែងរដ្ឋ អ្នកសង្កេតការណ៍ត្រូវពិនិត្យថា តើវាជាសកម្មភាពរបស់គណបក្សនយោបាយដែរឬទេ ? អ្នកសង្កេតការណ៍ អាចដឹងតាមរយៈការមើលដោយផ្ទាល់ ។*

**គ. សម្ភារៈបរិក្ខាររបស់រដ្ឋ៖** ដូចជាយានជំនិះគ្រប់ប្រភេទ ឬបរិក្ខាការិយាល័យដែលជារបស់រដ្ឋ (លើកលែងឡានរដ្ឋសភា និងព្រឹទ្ធសភា) ដែលមានស្លាកលេខ " រាជការ រដ្ឋ រដ្ឋាភិបាល នគរបាល(ន.ប) ខេមរភូមិន្ទ (ខ.ម) " ត្រូវបានប្រើប្រាស់ក្នុងសកម្មភាពបម្រើឲ្យគណបក្សនយោបាយដូចជាក្នុងពេលកិច្ចប្រជុំគណបក្ស ការចែកអំណោយរបស់គណបក្ស ការឃោសនារបស់គណបក្ស ។ល។

***ការណែនាំ៖*** *ចំពោះយានជំនិះយើងអាចសំគាល់ដឹងតាមរយៈស្លាកលេខយានជំនិះនោះ។ ចំពោះគ្រឿងបរិក្ខារផ្សេងទៀតប្រហែលជាពិបាកកំណត់។ ក៏ប៉ុន្តែ គ្រឿងបរិក្ខារមួយចំនួនគឺមានដាក់អក្សរជាកម្មសិទ្ធិរបស់ស្ថាប័ន។ ដូចនេះអ្នកសង្កេតការណ៍ត្រូវពិនិត្យមើលសម្ភារៈទាំងនោះ។*

*គ្រឿងបរិក្ខារ យាន្តជំនិះរដ្ឋទាំងអស់មិនត្រូវប្រើបំរើឲ្យគោលបំណងគណបក្សនយោបាយឡើយ។ ដូចនេះ មិនថានាយករដ្ឋមន្ត្រី ឬសមាជិកគណបក្សនយោបាយ ឬប្រជាពលរដ្ឋធម្មតា ឬអ្នកណាជាអ្នកប្រើប្រាស់គ្រឿងបរិក្ខារ ឬយានជំនិះរដ្ឋសម្រាប់បំរើឲ្យគណបក្សនយោបាយ គឺត្រូវតែកត់ត្រា និងសង្កេត។*

**ឃ. ហិរញ្ញវត្ថុគណបក្សនយោបាយ៖** គម្រោង ឬថវិកាជាតិនានារបស់រដ្ឋត្រូវបានយកមកបំផ្លែ ឬកេងចំណេញទៅជារបស់គណបក្សនយោបាយ ឬភ្ជាប់គណបក្សនយោបាយទៅនឹងសមិទ្ធផល ឬគម្រោងនានារបស់រដ្ឋ។ ដូចជា ការកសាងសាលារៀនដែលជាថវិការបស់រដ្ឋ តែដាក់ស្លាកគណបក្សនយោបាយ ឬការភ្ជាប់ទៅនឹងការសាងសង់នោះទៅនឹងគណបក្សនយោបាយ។

**ការណែនាំ៖** *នៅក្នុងដំណាក់កាលនេះ ការសង្កេតសកម្មភាពនេះមិនទាន់ត្រូវបានអនុវត្តទេ។*

**២របៀបនៃការសង្កេត និងការប្រមូលព័ត៌មាន៖ .**

ការប្រមូលព័ត៌មានទាក់ទងនឹងការប្រើប្រាស់ធនធានស្ថាប័នរដ្ឋ សម្រាប់បំរើឲ្យគណបក្ស នយោបាយនឹងធ្វើឡើងតាមវិធីសាស្ត្រ៣យ៉ាងសម្រាប់គម្រោងនេះ៖

**២.១. ការសង្កេតដោយផ្ទាល់**

ការសង្កេតដោយផ្ទាល់ គឺជាការប្រមូលព័ត៌មានបឋមដែលធនធានរដ្ឋត្រូវបានប្រើប្រាស់សម្រាប់បំរើឲ្យគណបក្សនយោបាយដោយអ្នកសង្កេតការណ៍ត្រូវស្ថិតនៅកន្លែងធ្វើសកម្មភាព ឬឃើញសកម្មភាព ឬរូបភាពនោះជាក់ស្តែងដោយផ្ទាល់ភ្នែក ឮដោយផ្ទាល់ត្រចៀក។

***ការណែនាំ៖*** *អ្នកសង្កេតការត្រូវតែជាអ្នកឃើញព្រឹត្តិការណ៍នៃការប្រើប្រាស់ធនធានរដ្ឋបំរើឲ្យគណបក្សនយោបាយដោយផ្ទាល់។ ដូចជាការមើលឃើញឡាន ម៉ូតូ ឬយានជំនិះផ្សេងដែលមានស្លាកលេខរដ្ឋ តែមានបិទស្លាកគណបក្សនយោបាយ ឬឡានត្រូវចតនៅក្នុងបរិវេណរបស់គណបក្សនយោបាយ ឬនៅក្នុងកិច្ចប្រជុំរបស់គណបក្សនយោបាយ។ ការចូលរួម និងឃើញសាលប្រជុំសាលាខេត្តត្រូវបានគណបក្សធ្វើជាទីកន្លែងប្រជុំ។ ការឮដោយផ្ទាល់ដែលមន្ត្រីរាជការនិយាយពីគណបក្សនយោបាយ។ល។*

**ក. ការទទួលបានព័ត៌មាន**

ជួនកាលអ្នកសង្កេតការណ៍អាចទទួលបានព័ត៌មានពីការរំលោភ/ភាពមិនប្រក្រតីនេះ នៅតាមទីធ្លាសាធារណៈ ដូចជាការឃើញឡានស្លាកលេខរដ្ឋ មានស្លាកគណបក្សនយោបាយអាចបិទជាប់នឹងឡាន ឬដាក់បង្ហាញ ក្នុងឡាននៅតាមទីសាធារណៈ ។ ការឃើញកងកម្លាំងប្រដាប់អាវុធដូចជានគរបាល ឬកងរាជអាវុធហត្ថ (ប៉េអឹម) ឬកងយោធពលខេមរភូមិន្ទ (ទាហាន) មានពាក់អាវ ឬមួកគណបក្សនយោបាយ ។ល។ ជួលកាលអ្នកសង្កេត ការណ៍អាចធ្វើដំណើរឆ្លងកាត់សាលាខេត្ត ហើយឃើញមានការប្រារព្ធពិធីរបស់គណបក្សនយោបាយ ។ល។

ទោះបីយ៉ាងណា អ្នកសង្កេតការណ៍ក៏ត្រូវស្វះស្វែងរកព័ត៌មាន សំខាន់ជាងនេះទៅទៀតដែរ ទាក់ទងនឹងការធ្វើសកម្មភាពផ្សេងទៀតរបស់គណបក្សនយោបាយ ដូចជាការប្រជុំ ការចែកអំណោយ និងពិធីផ្សេងៗទៀតរបស់គណបក្ស។

ជាទូទៅ ព័ត៌មានទាំងនេះអាចរកបានតាមរយៈគណបក្ស ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ អាជ្ញាធរ ប្រជាពលរដ្ឋ ។ល។ ការប្រជុំរបស់គណបក្សអាចត្រូវធ្វើឡើងជាសាធារណៈ ឬអសាធារណៈ ចំណែកការចែក អំណោយជារឿយៗ គឺនឹងត្រូវធ្វើឡើងជាសាធារណៈ ។

នៅក្នុងសកម្មភាពអ្វីក៏ដោយ គឺអ្នកសង្កេតការណ៍ត្រូវសង្កេតមើល និងប្រមូលព័ត៌មានពីអ្វីដែលខ្លួនត្រូវបានកំនត់ឲ្យចង់បាន ។

***ការណែនាំ៖*** *ព័ត៌មានគឺនៅជុំវិញខ្លួនយើង ប៉ុន្តែត្រង់ថាព័ត៌មានណាដែលយើងត្រូវយក និងព័ត៌មានណាដែលយើងមិនត្រូវយក។ ដូចនេះខាងក្រោមគឺជាសំណួរខ្លះៗដែលអ្នកសង្កេតអាចគិតក្នុងចិត្តដើម្បី៖*

*- តើមានសកម្មភាព ឬកម្មវិធីរបស់គណបក្សនយោបាយដែរឬទេ ?*

*- ទីកន្លែងដែលប្រើប្រាស់សម្រាប់សកម្មភាពនោះ ជាកន្លែងរបស់រដ្ឋឬ?*

*- អ្នកចូលរួមក្នុងកម្មវិធីនោះ ជាបុគ្គលិករាជការ កងកម្លាំងប្រដាប់អាវុធ?*

*- សម្ភារៈប្រើប្រាស់ និងយានជំនិះជារបស់រដ្ឋឬ?*

*- ទ្រព្យសម្បត្តិរបស់រដ្ឋមានដាក់ស្លាកសញ្ញា ឬឃោសនាឲ្យគណបក្សនយោបាយណាដែរឬទេ?*

